**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| តុលាការខេត្តកំពង់ធំ |
| សំណុំរឿងព្រហ្មទណ្ឌ |
| លេខ ៣២០ ចុះថ្ងៃទី ០៦ |
| ខែ វិច្ឆិកា ឆ្នាំ ២០០២ |
| សាលក្រម |
| លេខ ៩៩ "គ" ចុះថ្ងៃទី ០៨ |
| ខែ កញ្ញា ឆ្នាំ ២០០៤ |

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកំពង់ធំ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅទីតុលាការខេត្តកំពង់ធំ នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោកស្រី [redacted] អនុប្រធានតុលាការខេត្តកំពង់ធំ

**តំណាងអយ្យការ**

រក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកំពង់ធំ

**ក្រឡាបញ្ជី**

លោកស្រី [redacted]

សាលក្រមនេះបានចូលស្ថាពរ កាលពីថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៦
រួចហើយដោយគ្មានគូក្តីណាចូលមកប្តឹងតាមកំណត់ច្បាប់ ។
កំពង់ធំ.ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៦
**ចៅក្រមជំនុំជំរះ**
[redacted]

**ដើម្បីជំនុំជំរះ**

លើជនជាប់ចោទឈ្មោះ **រ សរ** ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិបុស្សជាម ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ សព្វថ្ងៃរស់នៅភូមិក្តីដូង ឃុំក្តីដូង ស្រុកស្ទឹងសែន ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ របររកស៊ីធ្វើមន្ត្រីរុក្ខាប្រមាញ់ ប្រពន្ធឈ្មោះ **គ ទណរ** មានកូន ០៥នាក់ ឪពុកឈ្មោះ **រេ ច** (ស) ម្តាយឈ្មោះ **ឈ គ** (ស) ទោសពីមុន *គ្មាន* ។

ពីបទ **បង្ករបួសស្នាមដោយចេតនាមានអាវុធ** ប្រព្រឹត្តនៅរុក្ខាប្រមាញ់ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ **ឈ ដទ** ភេទស្រី អាយុ ៣៥ឆ្នាំ នៅភូមិព្រៃតាត្រាវ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ប្តឹងថា កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១ វេលាម៉ោង ១១:៤០នាទីថ្ងៃត្រង់ ខ្លួននៅកន្លែងផ្ទៃកមេព្រៃ ទៅខ្ចីប្រាក់ ១០០ដុល្លា ពីឈ្មោះ **រ សរ** ជាប្តី ពេលនោះគាត់ទាញពិលមកវាយខ្លួន និង ទះកំផ្លៀងខ្លួនថែមទៀត ត្រូវថ្ពាល់បណ្តាលឱ្យជាំ ។

សំណូមពរផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ទាមទារជំងឺចិត្ត ០៣លានរៀល ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៥២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៤ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ធំ ។



Scanned with CamScanner

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១២៣៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៤ របស់ចៅក្រម ស៊ើបសួរ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១២៣៥ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៤ របស់ ប្រធានតុលាការខេត្តកំពង់ធំ ។

## ឯករឿងហេតុមានដូចតទៅ

ឈ្មោះ ល ជទ ជាសាហាយស្មន់នឹងគ្នា ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១ បានទៅជួប ៖ សរ នៅសង្កាត់ វក្លាប្រមាញ់ខេត្តកំពង់ធំ សុំយកប្រាក់ ១០០ដុល្លា ជាចំណែកម៉ូតូ ដោយសុំចង់បែកផ្លូវគ្នា ៖ សរ សុំលក់សិន ឈ្មោះ ល ជទ ថា លក់ក៏លក់ទៅឈ្មោះ ៖ សរ ខឹងទាញពិលវាយ និង ទះកំផ្លៀងថែមទៀត អស់ចិត្តទើបឈប់ ។

## នាពេលសវនាការ

អានចម្លើយជនជាប់ចោទឈ្មោះ ៖ សរ បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១ វេលាម៉ោង ១១.៤០នាទីថ្ងៃត្រង់ ឈ្មោះ ល ជទ ជាប្រពន្ធលួចលាក់បានមករករឿងខ្លួន ពេលសុំប្រាក់ ១០០ដុល្លា ខ្លួនថា យកម៉ូតូលក់ ពេលនោះ ល ជទ អូសម៉ូតូចេញ ខ្លួនចាប់ម៉ូតូទុកខ្លួនថា នាងឯងចង់បានតែប្រាក់ គាត់តមាត់ ហើយនៅតែអូសម៉ូតូចេញខ្លួនឃាត់មិនស្តាប់ ទះកំផ្លៀង ០២ដៃ ពេលនោះគេជួយឃាត់ ខ្លួនជិះម៉ូតូចេញ សូម តុលាការជួយរកយុត្តិធម៌ផង ។ កន្លងមកខ្លួនតែងទិញខោអាវ គ្រឿងអលង្ការឱ្យ មិនមែនខ្លួនជំពាក់ប្រាក់នាងនេះ ទេ ។

ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ល ជទ បានឆ្លើយបញ្ជាក់ថា នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១ វេលា ម៉ោង ១១.៤០នាទី ខ្លួនបានទៅរកលុយឈ្មោះ ៖ សរ ចំនួន ១០០ដុល្លា មូលហេតុខ្លួន និង គាត់បានគ្នានៅឆ្នាំ ១៩៩៤ ដែលគាត់មានប្រពន្ធរួចហើយ ។ ពេលនោះគាត់ថា គ្មាន ទាល់តែយកម៉ូតូទៅលក់ ខ្លួនថា លក់ក៏លក់ទៅ ពេលនោះគាត់ខឹងទាញពិល ០៣កំណាត់ មកវាយខ្លួនចំត្រគៀក និង ទះកំផ្លៀងជាច្រើនដៃបណ្តាលឱ្យជាំ ។ គាត់ ជំពាក់ប្រាក់ខ្លួន ៦៥០ដុល្លា ឯម៉ូតូមានចំណែកប្រាក់ខ្លួនដែរ ខ្លួនមានបំណងបែកពីគ្នា បានទាមទារយកប្រាក់វិញ ។ សុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ទាមទារជំងឺចិត្ត ០៣លានរៀល ។

អានចម្លើយសាក្សីឈ្មោះ ស ម បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១ វេលាម៉ោង ១១ថ្ងៃត្រង់ ខ្លួនអង្គុយលេងកន្លែងមេព្រៃ ក្រោយ ១០នាទី ឈ្មោះ ល ជទ ទៅសួរឈ្មោះ ៖ សរ និង ខ្ចីលុយ ១០០ដុល្លា ៖ សរ ឆ្លើយតបវិញមិនឮគេថា យ៉ាងណាទេ ស្រាប់តែគាត់វាយ ល ជទ ខ្លួនបានជួយចាប់បំបែក ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ឈ្មោះ ៖ សរ ពិតជាបានវាយនាង ល ជទ ពិតប្រាកដ ។ អយ្យការរក្សាបទចោទដដែល សូមតុលាការសំរេចសេចក្តីនេះទៅតាមច្បាប់ ។ ឯសំណងសំរេចតាមការជាក់ស្តែង ។

-ក្រោយពីបានអានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានអានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់អយ្យការ

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់



Scanned with CamScanner

**តុលាការខេត្តកំពង់ធំ**

**យល់ឃើញថា**

-ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១ ឈ្មោះ រ សរ បានវាយឈ្មោះ ល ជទ និង ពិលរូចទះកំផ្លៀងថែមទៀត ។

-ឈ្មោះ រ សរ មានចេតនាវាយទៅលើអ្នករងគ្រោះដោយខឹង និង មានការប្រកែកគ្នាដោយការទាមទារយកលុយដែលអ្នកទាំងពីរមានទំនាក់ទំនងគ្នារយៈកាល ០៥ឆ្នាំ មកហើយ ។

-ឈ្មោះអ្នករងគ្រោះត្រូវឈ្មោះ រ សរ វាយដំតែត្រូវបានអ្នកនៅទីនោះជួយឃាត់ទើបឈប់ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន រក្សាបទចោទដដែល សូមតុលាការសំរេចសេចក្តីទៅតាមច្បាប់ ។

-ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះបានសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ និង ទាមទារជំងឺចិត្ត ០៣លានរៀល តុលាការពិចារណា ។

-ឈ្មោះ រ សរ ល្មើសនឹងមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ហេតុដូច្នេះតុលាការខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសឈ្មោះ រ សរ ភេទប្រុស អាយុ ៤០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៦ខែ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង ០៥ឆ្នាំ ។ ពីបទ អំពើបង្ករបួសស្នាមដោយចេតនាមានអាវុធ ប្រព្រឹត្តនៅសង្កាត់វត្តប្រមាញ់ខេត្តកំពង់ធំ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១, ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ទោសខាងលើនេះ គិតតាំងពីថ្ងៃអនុវត្តសាលក្រមចូលស្ថាពរ ។

២-ឱ្យឈ្មោះ រ សរ ជូសជុលជំងឺចិត្តជាប្រាក់ ២០ម៉ឺនរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ល ជទ បណ្តឹងលើសពីនេះត្រូវលើកចោល ។ បើឈ្មោះ រ សរ មិនមានប្រាក់បង់ទេ បង្ខំរូបកាយដាក់គុកទារប្រាក់ធនទណ្ឌ ។

៣-សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនល្មើស ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**បានឃើញ**

**ចៅក្រមជំនុំជំរះតុលាការខេត្តកំពង់ធំ**

[redacted]

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខានិងត្រា**

[redacted]



Scanned with CamScanner